# គំរូការថវិកា និង ធនធានមនុស្ស និង ភាពជាដៃគូ

ការគណនា និង ការដាក់បញ្ចូលទៅក្នុងផែនការអប់រំសំរាប់ទាំងអស់គ្នានូវការចំណាយនានាដើម្បីសំរេចទិសដៅសមភាពយេនឌ័រ គឺជាការចាំបាច់ ។ ព្រមពេលជាមួយគ្នានេះដែរ ការកំណត់ពេលវេលាច្បាស់លាស់លើការផ្សព្វផ្សាយយេនឌ័រឱ្យបានទូលំទូលាយ និង មាននិន្នន័យគាំទ្រឥទ្ធិពលវិជ្ជមានដែលបានមកពីការអប់រំយេនឌ័រ ក៏ជាការសំខាន់ផងដែរនៅក្នុងសង្គម ។ ម្យ៉ាងវិញទៀត ការប្រើប្រាស់ធនធានមនុស្សចាំបាច់ និង **ការបណ្តុះ បណ្តាល ការធ្វើវិក្រឹតការ និង ការលើកកំពស់ចំណេះដឹង**បុគ្គលិក រួមមាន អ្នកគ្រប់គ្រង និង អ្នកត្រួតពិនិត្យ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងយេនឌ័រគំរូវឱ្យមានការគិតពិចារណាឱ្យបានល្អិតល្អន់ ។ ដើម្បីអនុវត្តផែនការអប់រំសំរាប់ទាំងអស់គ្នា និង យុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រឱ្យបានកាន់តែប្រសើរ ក្រសួងអប់រំអាចធ្វើការផ្លាស់ប្តូរស្ថាប័នមួយចំនួន។ តាមពិត ការផ្លាស់ប្តូរដូចនេះគឺជាការចាំបាច់នៅក្នុងប្រទេសមួយចំនួន។ជាឧទាហរណ៍ ការផ្លាស់ប្តូរអាចត្រូវការចាំបាច់ក្នុងការយកផ្នែកអប់រំរបស់ក្មេងស្រីចេញពីគំរោងដែលយកចិត្តទុកដាក់ទៅលើការអប់រំកុមារីប៉ុណ្ណោះទៅជាស្ថាប័នផ្តល់ប្រឹក្សាច្រើនផ្នែក និងត្រួតពិនិត្យដែលមានការគ្រប់គ្រងការអប់រំកំរិតខ្ពស់ ។ **ចំណុចបង្គោលយេនឌ័រ ឬ មន្ត្រីកម្មវិធីយេនឌ័រ**អាចត្រូវបានគេជ្រើសរើសនៅថ្នាក់ខេត្ត ឬ ស្រុក ក៏ដូចជាក្នុងនាយកដ្ឋាន អង្គភាព ឬ ស្ថាប័នជំនាញផ្សេងទៀតរបស់ក្រសួងអប់រំ(ដូចជា មជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ នាយកដ្ឋានកម្មវិធីសិក្សា ជាដើម) ។ ការកំណត់ឱ្យមានធនធាន និង សិទ្ធិអំណាច នៅគ្រប់កំរិតនីមួយៗសំរាប់សកម្មភាពអនុវត្ត គឺជាការចាំបាច់បំផុត។

បញ្ហាយេនឌ័រក្នុងវិស័យអប់រំមានលក្ខណៈស្មុគស្មាញ។ មានកត្តាជាច្រើនដែលទាក់ទងទៅនឹងស្ថានភាពសាលារៀន សេដ្ឋកិច្ចសង្គម និង វប្បធម៌ដែលទាមទារឱ្យមានការចូលរួមពីភាគីផ្សេងៗ ដើម្បីកំណត់រកបញ្ហា និង យុទ្ធសាស្រ្ត។ ភាពជាដៃគូពីអន្តរស្ថាប័ន ក្រុមគាំទ្រ ។ល។ សំរាប់ការអប់រំក្មេងស្រី ដែលមានការពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សហគមន៍ជំនួញ បណ្តាញព័ត៌មាន អង្គការសាសនា ស្ថាប័នរដ្ឋាភិបាល និង

Guide.qxp 1/03/2005 4:10 PM Page 33

អង្គការអន្តរជាតិនានា បានបង្ហាញឱ្យឃើញពីជោគជ័យយ៉ាងធំធេងនៅក្នុងប្រទេសជាច្រើន [១]។

មានប្រទេសកាន់តែច្រើនឡើងៗបានអនុម័ត *វិធីសាស្ត្រចំរុះស្ថាប័ន* ដើម្បីអប់រំអ្នកផ្តល់ជំនួយ និង ទីភ្នាក់ងារបច្ចេកទេសមួយចំនួនអំពីផែនការអភិវឌ្ឍន៍លំអិតសំរាប់វិស័យអប់រំ ដោយមានរដ្ឋាភិបាលជាអ្នកដឹកនាំ។ ការស្រាវជ្រាវបង្ហាញថា នៅពេលដៃគូទាំងអស់មានការប្តេជ្ញាខ្ពស់ និង មានចំណាប់អារម្មណ៍លើបញ្ហាយេនឌ័រ ពេលនោះការកែប្រែអាចកើតមានឡើងក្នុងវិស័យអប់រំ ។ ទោះជាយ៉ាងនេះក៏ដោយ ករណីនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ការតស៊ូមតិទូលំទូលាយ និង សកម្មភាពលើកកំពស់ការយល់ដឹងក៏ជាការចាំបាច់ក្នុងចំណោមដៃគូទាំងអស់ផងដែរ ។ ការបណ្តុះបណ្តាលយេនឌ័រទាក់ទងនឹងការពិនិត្យឡើងវិញនៃការអនុវត្តប្រចាំឆ្នាំ ឬ កន្លះឆ្នាំរបស់អ្នកចូលរួមទាំងអស់ (មន្ត្រីរដ្ឋាភិបាល និង តំណាងម្ចាស់អំណោយ) អាចជា វិធីមួយធ្វើឱ្យមានការឯកភាព និង សកម្មភាពរួមក្នុងចំណោមភាគីពាក់ព័ន្ធ។

ការអប់រំដើម្បីឆ្លើយតបទៅនឹងយេនឌ័រ គឺជាផ្នែកគន្លឹះដល់ការកាត់បន្ថយភាពក្រីក្រ និង ធ្វើឱ្យមានការកែប្រែ និង រីកចំរើនវិជ្ជមានក្នុងស្រទាប់ប្រជាជន។ ទោះជាយ៉ាងនេះក៏ដោយ គំរោងអភិវឌ្ឍជាច្រើនផ្តល់សេវា ឬ យកចិត្តទុកដាក់តែសំបកក្រៅដល់បញ្ហាយេនឌ័រ ហើយជាពិសេស ចំពោះតួនាទីនៃការអប់រំដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។ ក្រសួងអប់រំ និង ភាគីពាក់ព័ន្ធខាងវិស័យអប់រំក្រៅរដ្ឋាភិបាលត្រូវតែមានការប្រុងប្រយ័ត្ន។ វិស័យអប់រំទាំងមូលចាំបាច់ត្រួតពិនិត្យឱ្យដឹងថា មានការលើកកំពស់ការអប់រំយេនឌ័រស្មើៗគ្នា ដោយមិនត្រូវប្រកាន់យកតែគំនិតអភិវឌ្ឍ ដែលមិនបានគិតគូរដល់យេនឌ័រឡើយ។ ការនេះទាមទារឱ្យភាគីពាក់ព័ន្ធក្នុង និង ក្រៅប្រព័ន្ធអប់រំចូលរួមសហការជាមួយផ្នែកសាធារណៈ ផ្នែកស៊ីវិល និង ឯកជន និង សហគមន៍អន្តរជាតិ ។ មានផ្នែកសំខាន់ជាច្រើនតំរូវឱ្យជំនាញការអប់រំ និង យេនឌ័រជួយសំរេចគោលដៅ អភិវឌ្ឍន៍ប្រចាំសហស្សវត្ស យុទ្ធសាស្ត្រ និង កម្មវិធីកាត់បន្ថយភាពក្រីក្រ និង ទិសដៅអភិវឌ្ឍសំខាន់ៗ ជាច្រើនទៀត។

១. សំរាប់ព័ត៌មានបន្ថែមអំពីគោលការណ៍ និង ការអនុវត្ត សូមមើល Williams, H., *Multisectoral Strategies for Advancing Girls'Education*, SAGE, Washington DC, 2001.